# ព្រឹត្តិបត្រព័ត៌មាន

STEP

Supported by 日本財団 THE NIPPON FOUNDATION

មូលនិធិគាំទ្រការបណ្ដុះបណ្ដាលសុខភាពសិក្សា និងការលើកកម្ពស់អេកូសុខភាព

លេខ ៣ | ថ្ងៃអង្គារ ១១រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹង ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦


## ដំណើរឆ្ពោះទៅកាន់ការបណ្ដុះបណ្ដាលសុខភាពសិក្សាតាមរយៈ អង្គការ STEP

### «វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី២ សៀមរាប ថ្ងៃទី២៨ ដល់៣០ ខែមេសា ឆ្នាំ២០២៦»



ក្រោមការគាំទ្រជាបន្តបន្ទាប់ពី មូលនិធិនីបប៉ុន (The Nippon Foundation) អង្គការ STEP នៅតែបន្តខិតខំប្រឹងប្រែងឆ្ពោះទៅកាន់អនាគតដែលមានសុខភាពល្អប្រសើរជាងមុនសម្រាប់សិស្សានុសិស្ស និងសហគមន៍នានានៅក្នុងប្រទេសកម្ពុជា។ ការបណ្ដុះបណ្ដាលនេះបានចាប់ផ្ដើមដោយសុន្ទរកថាបើកដ៏មានអត្ថន័យពីថ្នាក់ដឹកនាំសំខាន់ៗរួមមាន តំណាងមកពី អង្គការ STEP នាយកដ្ឋានសុខភាពសិក្សា និងស្ថាប័នដៃគូពាក់ព័ន្ធ។ វត្តមាននាថ្ងៃនេះ បានគូសបញ្ជាក់អំពីការប្ដេជ្ញាចិត្តរួមគ្នា ភាពជាដៃគូសហការយូរអង្វែង និងទស្សនវិស័យរួមក្នុងការលើកកម្ពស់សុខុមាលភាពរបស់សិស្សានុសិស្សទូទាំងប្រទេសកម្ពុជា។

## កម្មវិធីបណ្ដុះបណ្ដាលរយៈពេល៣ថ្ងៃ

នេះគឺជាការបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី២ របស់អង្គការ STEP។ ចក្ខុវិស័យនៃការបណ្ដុះបណ្ដាលនេះគឺប្លែកជាងវគ្គបណ្ដុះបណ្ដាលទូទៅ ព្រោះមិនត្រឹមតែមានការបណ្ដុះបណ្ដាល និងសិក្សានៅនឹងកន្លែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានដំណើរទស្សនកិច្ចទៅកាន់ទីតាំងជាក់ស្ដែងផងដែរ។ គោលបំណងគឺដើម្បីឱ្យអ្នកចូលរួមអាចយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពសុខភាពសិក្សាពិតប្រាកដនៅកម្ពុជាតាមរយៈការទទួលបទពិសោធន៍ផ្ទាល់។

APRIL 28

**ខ្លឹមសារនៃការបណ្ដុះបណ្ដាលសុខភាពសិក្សាសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ**

- កម្មវិធីបើក
- បទឧទ្ទេសអំពីសុខភាពសិក្សាដោយសាស្ត្រាចារ្យមកពីប្រទេសជប៉ុន

APRIL 29

**ដំណើរទស្សនកិច្ច**

- ទស្សនកិច្ចសិក្សា
- សកម្មភាពសុខភាពសិក្សានានាដោយគ្រូឧទ្ទេសសុខភាពសិក្សា

APRIL 30

**វគ្គបណ្ដុះបណ្ដាលស្ដីពី ការបកប្រែសៀវភៅសិក្សាគោល**

- ការកែសម្រួលសន្នានុក្រម
- ពិភាក្សាក្រុម ការបញ្ចេញមតិ

## ថាមពលនៃការបណ្តុះបណ្តាលប្រកបដោយអត្ថន័យ និងលទ្ធផលល្អ

លើកនេះ អង្គការ STEP បានរៀបចំការបណ្តុះបណ្តាលនៅខេត្តសៀមរាប ដើម្បីឱ្យគ្រូឧទ្ទេសសុខភាពសិក្សា និងបុគ្គលិកទាំងអស់អាចផ្តោតអារម្មណ៍លើខ្លឹមសារបណ្តុះបណ្តាលបានពេញលេញ ដោយគ្មានការរំខានពីកិច្ចការផ្សេងៗ។ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃនេះ បានរៀបចំឱ្យមានជាសកម្មភាពចម្រុះ មានអត្ថន័យ និងផ្តល់លទ្ធផលប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទោះបីជារយៈពេលមានកំណត់ក៏ដោយ ក្តីរំពឹងគឺច្បាស់លាស់ថា រាល់វគ្គសិក្សា ការពិភាក្សា និងបទពិសោធន៍នៅទីតាំងជាក់ស្តែង នឹងរួមចំណែកដល់ការយល់ដឹងកាន់តែស៊ីជម្រៅ និងល្អប្រសើរ សម្រាប់ការអនុវត្តជាក់ស្តែង។



*កញ្ញា ម៉ាស៊ឹកុ យ៉ឹកា នាយកប្រចាំប្រទេស អង្គការ STEP*



*លោកសាស្ត្រាចារ្យបណ្ឌិត អាសាគីអ៊ុ តាកាស៊ី ប្រធានអង្គការ STEP*

## សុខភាព សន្តិភាព និងអនាគតនៃការអប់រំ

វគ្គបណ្តុះបណ្តាលសុខភាពសិក្សាលើកទី២របស់អង្គការ STEP បានប្រារព្ធឡើងនៅខេត្តសៀមរាប មិនត្រឹមតែជាសិក្ខាសាលាបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែជាការឆ្លុះបញ្ចាំងអំពីទំនាក់ទំនងជិតស្និទ្ធរវាងសន្តិភាព និងការអប់រំ។ ក្នុងបរិបទនៃជម្លោះថ្មីៗនៅជិតខេត្តសៀមរាប យើងទាំងអស់គ្នាបានចងចាំថា អស្ថិរភាពមិនត្រឹមតែប៉ះពាល់ដល់សុវត្ថិភាព និងសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ការសិក្សារបស់កុមារ ជីវភាពគ្រួសារ និងសុខុមាលភាពរបស់សហគមន៍ផងដែរ។ ដោយផ្អែកលើគំនិត «សុខភាពដើម្បីសន្តិភាព» របស់អង្គការ WHO វគ្គនេះបានសង្កត់ធ្ងន់ថា ការអប់រំអាចជួយកសាងទំនុកចិត្ត កាត់បន្ថយភាពតានតឹង និងបណ្តុះក្តីសង្ឃឹមសម្រាប់អនាគតដែលមានសន្តិភាពកាន់តែប្រសើរ។

ការពិភាក្សាក៏បានលើកឡើងពីសារៈសំខាន់នៃការឱ្យសហគមន៍ក្នុងស្រុកមានតួនាទីសំខាន់ក្នុងវិស័យអប់រំ ជាពិសេសក្នុងការរៀបចំសៀវភៅសុខភាពសិក្សានៅកម្ពុជា។ អ្នកចូលរួមបានយល់ថា ការអប់រំដែលល្អ និងមានន័យពិតប្រាកដ ត្រូវតែផ្អែកលើស្ថានភាពជាក់ស្តែង វប្បធម៌ និងបទពិសោធន៍មូលដ្ឋាន។ ដោយមានការគាំទ្រពី មូលនិធិនីបប៉ុន(The Nippon Foundation) គម្រោងនេះត្រូវបានចាត់ទុកថាជាចំណុចចាប់ផ្តើមមួយ។ ផលប្រយោជន៍រយៈពេលវែងរបស់វា នឹងអាស្រ័យលើការចូលរួមបន្តរបស់អ្នកអប់រំកម្ពុជា ក្នុងការរៀបចំ និងពង្រឹងការអប់រំសុខភាពសិក្សាឱ្យកាន់តែមានភាពរឹងមាំ។

វគ្គបណ្តុះបណ្តាលបានបញ្ចប់ដោយការប្តេជ្ញារួមគ្នា ក្នុងការបន្តជំរុញសន្តិភាព និងពង្រឹងអនាគតនៃវិស័យអប់រំនៅកម្ពុជា ឱ្យកាន់តែរីកចម្រើន និងមាននិរន្តរភាព។

## \លំហាត់ប្រាណ/



វគ្គបណ្តុះបណ្តាលរបស់ អង្គការ STEP ចាប់ផ្តើមរៀងរាល់ព្រឹកដោយការធ្វើលំហាត់ប្រាណបែបប្រពៃណីរបស់ជនជាតិជប៉ុន។ លំហាត់ប្រាណពេលព្រឹកនេះជួយឱ្យអ្នកចូលរួមចាប់ផ្តើមថ្ងៃថ្មីដោយអារម្មណ៍ស្រស់ស្រាយ និងមានថាមពលល្អ។





# មតិសំណេះសំណាលថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា




*ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ*
*អនុប្រធាននាយកដ្ឋានសុខភាពសិក្សា*

## ការប្តេជ្ញាចិត្តក្នុងការជំរុញ និងពង្រឹងការអប់រំសុខភាព

ក្នុងមតិសំណេះសំណាលបើកកម្មវិធី ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ អនុប្រធាននាយកដ្ឋានសុខភាពសិក្សា បានសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្រ ចំពោះ មូលនិធិនីបប៉ុន (The Nippon Foundation) សម្រាប់ការគាំទ្របន្តឥតឈប់ឈររបស់ខ្លួន។ ថ្លែងសុន្ទរកថាពីខេត្តសៀមរាប ឯកឧត្តមវេជ្ជបណ្ឌិតបានគូសបញ្ជាក់ពីសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រ និងវប្បធម៌របស់ទីក្រុងនេះ។ លោកក៏បានសម្តែងការកោតសរសើរ ចំពោះ លោកសាស្ត្រាចារ្យបណ្ឌិត អាសាគីរ៉ា តាកាស៊ី ចំពោះការឆ្លុះបញ្ចាំងរបស់លោកអំពីសង្គ្រាមឈ្លានពានថៃ ដោយទទួលស្គាល់ថាបញ្ហានេះមានភាពរសើប ជាពិសេសចំពោះគ្រួសារដែលបានរងផលប៉ះពាល់ពីការបាត់បង់ និងការផ្លាស់ទីលំនៅ។

ឯកឧត្តមវេជ្ជបណ្ឌិតបានថ្លែងអំណរគុណដល់បុគ្គលិក STEP និងគ្រូឧទ្ទេសនៃវិទ្យាស្ថានទាំងពីរចំពោះការខិតខំ និងការចូលរួមយ៉ាងសកម្ម។ ឯកឧត្តមក៏បានបញ្ជាក់ថា វគ្គបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃនេះមានសារៈសំខាន់ខ្លាំងណាស់។ បន្ថែមពីនេះ ឯកឧត្តមបានលើកទឹកចិត្តគ្រូឧទ្ទេសឱ្យមានការទទួលខុសត្រូវក្នុងការរៀបចំសៀវភៅសិក្សាគោល ចំនួន២៤ ក្រេឌីត ជាពិសេសផ្នែកបកប្រែ និងការអនុវត្តដោយផ្តោតលើគុណភាព ភាពច្បាស់លាស់ រូបភាពស្អាត និងភាពងាយអាន ដើម្បីជួយឱ្យសិស្សរៀនបានល្អ។

នៅចុងបញ្ចប់នៃសន្ទរកថា ឯកឧត្តមវេជ្ជបណ្ឌិតបានបង្ហាញការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ចំពោះការខិតខំប្រឹងប្រែងរបស់អង្គការ STEP និងគ្រូឧទ្ទេសសុខភាពសិក្សានៃវិទ្យាស្ថានទាំងពីរ ព្រមទាំងការរំពឹងទុកពីក្រសួងអប់រំ យុវជន និងកីឡាចំពោះលទ្ធផលគម្រោង SHCC ដំណាក់កាលទី២ នាពេលអនាគត។ ឯកឧត្តមក៏បានផ្តល់សារលើកទឹកចិត្តយ៉ាងខ្លាំង ដោយជំរុញឱ្យអ្នកចូលរួមទាំងអស់បន្តខិតខំឆ្ពោះទៅរកឧត្តមភាពក្នុងការជំរុញវិស័យសុខភាពសិក្សាសម្រាប់ជំនាន់ក្រោយរបស់កម្ពុជា។

# បទឧទ្ទេសអំពីខ្លឹមសារសៀវភៅសិក្សាគោល

## សុខភាពសិក្សា និងសុវត្ថិភាពសាលារៀន

ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសដំបូង បានពិភាក្សាអំពីគោលគំនិតសំខាន់ៗនៃសុខភាពសិក្សា និងសុវត្ថិភាពសាលារៀន។ ក្រោមការណែនាំរបស់គ្រូឧទ្ទេសជំនាញផ្នែកសុខភាពសិក្សា អ្នកចូលរួមបានពង្រឹងការយល់ដឹងអំពី សារៈសំខាន់នៃបរិយាកាសសាលាដែលមានសុវត្ថិភាព និងសុខភាពល្អ ដែលអាចជួយឱ្យការសិក្សាមានប្រសិទ្ធភាព និងគាំទ្រដល់ការអភិវឌ្ឍរបស់កុមារ។

**ដោយ Dr. Saito Chikage និង Dr. Aoyagi Naoko**




## កាយវិភាគវិទ្យា និងសរីរវិទ្យា

ដោយផ្អែកលើចំណេះដឹងមូលដ្ឋាន បទឧទ្ទេសផ្នែកទីពីរបានផ្តោតលើកាយវិភាគវិទ្យា និងសរីរវិទ្យា។ គ្រូឧទ្ទេសសុខភាពសិក្សាបានពង្រឹងការយល់ដឹងអំពីរចនាសម្ព័ន្ធ និងមុខងាររបស់រាងកាយមនុស្ស ដើម្បីអាចប្រើប្រាស់ចំណេះដឹងនេះក្នុងការបង្រៀនមុខវិជ្ជាសុខភាពសិក្សានៅក្នុងវិទ្យាស្ថានគរុកោសល្យឱ្យមានប្រសិទ្ធភាព។

**បទឧទ្ទេសដោយ Dr. Aoyagi Naoko**



# ទស្សនកិច្ចសិក្សានៅសាលាចងសម្ព័ន្ធមេត្រីភាពនៃវិទ្យាស្ថានគរុកោសល្យទាំងពីរ




*វិទ្យាស្ថានគរុកោសល្យ សូមសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅ និងគោរពខ្ពស់ជាទីបំផុតចំពោះ មូលនិធិនីបប៉ុន (The Nippon Foundation) អង្គការ STEP គ្រូឧទ្ទេសសុខភាពសិក្សា និងភាគីពាក់ព័ន្ធក្នុងសហគមន៍ ចំពោះកិច្ចសហការបន្ត និងភាពរឹងមាំក្នុងការរួមចំណែកគាំទ្រតម្រូវការរបស់សិស្សានុសិស្ស និងគ្រួសារដែលបានផ្លាស់ទីលំនៅ។*

ជម្លោះថ្មីៗនៅតាមបន្ទាត់ព្រំដែនកម្ពុជា បានប៉ះពាល់យ៉ាងខ្លាំងដល់គ្រួសារ និងសហគមន៍រួមទាំងសាលាចងសម្ព័ន្ធមេត្រីភាពនៃវិទ្យាស្ថានគរុកោសល្យទាំងពីរ គឺសាលាបឋមសិក្សាបុស្សធំ (PTEC) និងសាលាបឋមសិក្សាតាមន្តសែនជ័យ (BTEC) ដែលបានជួបការរំខានយ៉ាងខ្លាំងពីសង្គ្រាមឈ្លានពាននេះ។ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងគ្រួសារជាច្រើនត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅ ខណៈកុមារនៅតែបន្តការសិក្សាក្នុងជំរុំបណ្ដោះអាសន្ន(តង់)។ ទោះជាមានឧបសគ្គទាំងនេះក៏ដោយ សិស្សានុសិស្សនៅតែបន្តប្តេជ្ញាចិត្តក្នុងការសិក្សារបស់ពួកគេក្នុងគ្រាលំបាកនេះ។

ជាការឆ្លើយតប **អង្គការ** STEP បានចុះទៅសាលាគោលដៅ និងសហការជាមួយគ្រូឧទ្ទេសសុខភាពសិក្សា ដើម្បីអនុវត្តសកម្មភាពលើកកម្ពស់សុខភាពសិក្សា និងអនាម័យ។ សកម្មភាពទាំងនេះរួមមាន លំហាត់ប្រាណ ការសម្អាតដៃ និងការថែទាំអនាម័យមាត់ធ្មេញ ដើម្បីគាំទ្រសុខុមាលភាពរបស់សិស្សានុសិស្សក្នុងអំឡុងពេលផ្លាស់ទីលំនៅ។

















## ការឆ្លុះបញ្ចាំងនៃដំណើរទស្សនកិច្ចសិក្សា

បន្ទាប់ពីដំណើរទស្សនកិច្ចសិក្សា គ្រូឧទ្ទេសសុខភាពសិក្សាបានឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមរបស់សិស្សានុសិស្សផ្លាស់ទីលំនៅកំពុងជួបប្រទះ និងបានលើកឡើងពីសារៈសំខាន់នៃការបន្តការសិក្សា ព្រមទាំងការគាំទ្រផ្នែកសុខភាពក្នុងអំឡុងពេលលំបាកនេះ។ គ្រូឧទ្ទេសសុខភាពសិក្សាបានសម្តែងការកោតសរសើរចំពោះភាពរឹងមាំរបស់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងគ្រួសារ ដោយកត់សម្គាល់ថា កុមារដែលរៀននៅក្នុងថ្នាក់បណ្តោះអាសន្ន (តង់) នៅតែចូលរួមសកម្ម និងមានចិត្តចង់រៀនសូត្រ។ ដំណើរទស្សនកិច្ចនេះក៏បានបញ្ជាក់បន្ថែមអំពីសារៈសំខាន់នៃអនាម័យ និងសុខុមាលភាពក្នុងបរិបទសិក្សាបន្ទាន់ ហើយក៏បានបញ្ចូលសកម្មភាពដូចជា **លំហាត់ប្រាណ ការលាងដៃ និងការថែទាំអនាម័យមាត់ធ្មេញ** ដើម្បីលើកកម្ពស់ទម្លាប់សុខភាពល្អ និងគាំទ្រសុខុមាលភាពផ្លូវអារម្មណ៍របស់សិស្សានុសិស្ស។

វិទ្យាស្ថានគរុកោសល្យ និងដៃគូរបស់ខ្លួននៅតែបន្តផ្តល់ការគាំទ្រដល់សាលារៀន និងសហគមន៍ដែលរងផលប៉ះពាល់ តាមលទ្ធភាពដែលអាចធ្វើបាន ដោយផ្តោតលើវិស័យអប់រំ ការលើកកម្ពស់ការយល់ដឹងអំពីសុខភាព និងសុខុមាលភាពរបស់សិស្សានុសិស្ស។







## វគ្គបណ្តុះបណ្តាលស្តីពី ការបកប្រែសៀវភៅសិក្សាគោល

### ការផ្សារភ្ជាប់ចំណេះដឹង៖ លើកកម្ពស់គុណភាពអប់រំតាមរយៈការបកប្រែសៀវភៅសិក្សាគោល

វគ្គបណ្តុះបណ្តាលស្តីពីការបកប្រែសៀវភៅសិក្សាគោល រៀបចំឡើងក្នុងគោលបំណងគាំទ្រការពង្រឹង និងកែលម្អខ្លឹមសារសៀវភៅសិក្សារួមគ្នា ព្រមទាំងលើកកម្ពស់គុណភាពឯកសារអប់រំឱ្យកាន់តែមានប្រសិទ្ធភាព។ វគ្គនេះបានប្រមូលផ្តុំគ្រូឧទ្ទេសសុខភាពសិក្សាឱ្យធ្វើការរួមគ្នាក្នុងការពិនិត្យ និងកែលម្អពាក្យបច្ចេកទេសសំខាន់ៗ តាមរយៈការរៀបចំសទ្ទានុក្រមឱ្យមានភាពច្បាស់លាស់ និងឯកភាពដើម្បីជានាការប្រើប្រាស់ពាក្យឱ្យបានត្រឹមត្រូវ និងស្របគ្នានៅក្នុងឯកសារទាំងអស់។

បន្ថែមពីនេះ ការអនុវត្តលំហាត់បកប្រែជាក់ស្តែង ក៏បានអនុវត្តដើម្បីពង្រឹងជំនាញរបស់គ្រូឧទ្ទេសសុខភាពសិក្សា ព្រមទាំងលើកកម្ពស់ការយល់ដឹងរួមអំពីវិធីសាស្ត្របកប្រែប្រកបដោយប្រសិទ្ធភាព។ ការពិភាក្សាជាក្រុម និងការផ្តល់មតិយោបល់គ្នាទៅវិញទៅមក ក៏បានអនុវត្តដើម្បីកំណត់ចំណុចដែលត្រូវកែលម្អ និងធ្វើឱ្យវិធីសាស្ត្របកប្រែកាន់តែមានគុណភាព និងភាពត្រឹមត្រូវ។

ជារួមវគ្គបណ្តុះបណ្តាលនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងស្តង់ដារបកប្រែ កែលម្អដើម្បីឱ្យមានភាពច្បាស់លាស់ និងភាពស្របគ្នា ព្រមទាំងគាំទ្រការអភិវឌ្ឍសម្ភារៈសិក្សាដែលមានគុណភាពខ្ពស់ សម្រាប់ការអនុវត្តក្នុងថ្នាក់រៀន។



ការកែសម្រួលសទ្ទានុក្រម



ការកែលម្អបញ្ញត្តិ និងគំរូនៃការបកប្រែ



ការបកប្រែអត្ថបទខ្លីៗ

## មិត្តឡប់ពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា




### លោក ម៉ន មុនិន្ទ ប្រធាន នាយកដ្ឋានកិច្ចការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលសុខភាពសិក្សាលើកទី២ របស់អង្គការ STEP ដែលបានប្រារព្ធឡើងនៅខេត្តសៀមរាប បានបើកកម្មវិធីដោយមានការឆ្លុះបញ្ចាំងសំខាន់ៗពីភាគីពាក់ព័ន្ធ ព្រមទាំងបានកំណត់ទិសដៅរួមក្នុងការពង្រឹង និងលើកកម្ពស់វិស័យអប់រំសុខភាពនៅកម្ពុជា។ វាគ្មិនកិត្តិយសបានលើកឡើងអំពីការកែលម្អជាបន្តបន្ទាប់ និង តួនាទីរបស់ការអប់រំសុខភាពក្នុងការលើកកម្ពស់សន្តិភាព និងភាពធន់។ លោកប្រធានក៏បានបញ្ជាក់អំពីសារៈសំខាន់នៃគុណភាព និងភាពស្របគ្នាក្នុងការរៀបចំសៀវភៅសិក្សាគោល ព្រមទាំងការប្រើប្រាស់ឧបករណ៍ស្តង់ដាដូចជា គំរូ និងសន្ទានុក្រមរួម ដើម្បីធ្វើឱ្យការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព។

ផ្នែកបច្ចេកទេសបទឧទ្ទេសដោយសាស្ត្រាចារ្យ Saito Chikage និង សាស្ត្រាចារ្យ Aoyagi Naoko បានពិភាក្សាអំពីសុខភាពសិក្សា និងសុវត្ថិភាពសាលារៀន ព្រមទាំងកាយវិភាគវិទ្យា និងសរីរវិទ្យា។ ផ្នែកទាំងនេះបានប្រើវិធីសាស្ត្របង្រៀនបែបអន្តរកម្មដូចជា ការសិក្សាករណី និងការពិភាក្សាជាក្រុម ដើម្បីជួយឱ្យគ្រូឧទ្ទេសសុខភាពសិក្សាយល់ដឹងកាន់តែច្បាស់ និងអាចអនុវត្តបានជាក់ស្តែង។ ជារួម វគ្គបណ្តុះបណ្តាលនេះបានផ្តោតលើការធ្វើឱ្យខ្លឹមសារបច្ចេកទេសស្របទៅនឹងស្ថានភាពជាក់ស្តែងក្នុងថ្នាក់រៀន ដើម្បីធានាថាសម្ភារៈសុខភាពសិក្សាមានភាពសមស្រប និងអាចប្រើប្រាស់បានយ៉ាងមានប្រសិទ្ធភាពនៅក្នុងសាលារៀនកម្ពុជា។



«អនាគតភ្លឺស្វាងក្រោមតង់សិក្សា»

*ការចែករំលែកសម្ភារៈសិក្សា និងការបង្កើតឱកាសសម្រាប់កុមារគ្រប់រូប*

## សុន្ទរកថាបិទពីគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យ

### លោកបណ្ឌិត សំ ច័ន្ទភិរុណ នាយករង វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ



នៅថ្ងៃចុងក្រោយនៃវគ្គបណ្តុះបណ្តាលលោកបណ្ឌិត សំ ច័ន្ទភិរុណ បានអញ្ជើញជាអធិបតីក្នុងពិធីបិទកម្មវិធីដោយជួយជម្រុញឱ្យអ្នកចូលរួមឆ្លុះបញ្ចាំង និងយល់អំពីគោលបំណងរួមរបស់កម្មវិធី។ ក្នុងសុន្ទរកថារបស់លោកបណ្ឌិត លោកបានផ្តល់អនុសាសន៍ដ៏មានតម្លៃ និងបានលើកទឹកចិត្តយ៉ាងខ្លាំងដល់គ្រូឧទ្ទេសសុខភាពសិក្សាអោយខិតខំប្រឹងប្រែងបន្ត និងប្តេជ្ញាចិត្តក្នុងការចូលរួមរាល់សកម្មភាពនានា ប្រកបដោយភាពឆ្នៃប្រឌិត ដើម្បីសម្រេចអោយបាននូវបេសកកម្មរបស់ អង្គការ STEP។ ជាមួយគ្នានេះដែរលោកបណ្ឌិត បានសម្តែងការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ មូលនិធិនីបប៉ុន (The Nippon Foundation) និង អង្គការ STEP ចំពោះការគាំទ្រជាបន្តបន្ទាប់ដល់វិទ្យាស្ថានគរុកោសល្យទាំងពីរ ព្រមទាំងបានគូសបញ្ជាក់អំពីភាពរឹងមាំនៃកិច្ចសហការដែលមានទំនុកចិត្តរវាងភាគីពាក់ព័ន្ធ។

ដោយឆ្លុះបញ្ចាំងពីដំណើរការកន្លងមក លោកបណ្ឌិតបានសម្តែងនូវក្តីសង្ឃឹមថា អង្គការ STEP នឹងបន្តភាពរីកចម្រើន និងពង្រីកសកម្មភាពរបស់ខ្លួននៅកម្រិតថ្នាក់ជាតិ ដោយមានការគាំទ្រយ៉ាងជិតស្និទ្ធពីវិទ្យាស្ថានគរុកោសល្យទាំងពីរ។ លោកបណ្ឌិតក៏បានលើកឡើងពីទិសដៅសំខាន់ៗនាពេលអនាគត ដើម្បីពង្រឹងការអភិវឌ្ឍវិស័យសុខភាពសិក្សារួមមាន ការរៀបចំវេទិកាសុខភាពសិក្សាប្រចាំឆ្នាំ ការពង្រឹងការចូលរួមរបស់សហគមន៍ និងស្ថាប័នពាក់ព័ន្ធ ការផ្តល់ឱកាសរៀនអនុវត្តជាក់ស្តែងសម្រាប់គរុនិស្សិត និងការពង្រីកវេទិកាជាតិ និងអនឡាញសម្រាប់ការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍រវាងភាគីពាក់ព័ន្ធ។

ជាចុងបញ្ចប់ លោកបណ្ឌិតបានចែករំលែកចក្ខុវិស័យក្នុងការកសាងអង្គការ STEP ឱ្យក្លាយជា **«សហគមន៍ STEP ដែលមានសុភមង្គល និងសុខភាពល្អ»** ដោយផ្តោតលើការអនុវត្តកិច្ចសហការជាក់ស្តែង និងផ្តល់អាទិភាពដល់សុខុមាលភាពរបស់សិស្សានុសិស្ស គ្រូឧទ្ទេស និងសហគមន៍។

**VOLUME 3 | 12 May, 2026**

## A JOURNEY THROUGH THE STEP SCHOOL HEALTH TRAINING

**"The 2nd School Health Lecturer Training in Siem Reap (28 – 30 April, 2026)"**



With the continued support of The Nippon Foundation, STEP is working toward a healthier future for students and communities in Cambodia. The training commenced with impactful opening remarks from key leaders, representatives from NGO STEP, the School Health Department, and partner institutions emphasized shared commitment, ongoing partnerships, and the collective vision to improve student well-being across Cambodia.

## 3 Days Training Program

This is the second School Health Lecturer Training organized by STEP. The vision of this program has gone beyond a typical training or workshop. It was designed not only for classroom learning, but also to include a field trip—so that participants could better understand the real situation of school health in Cambodia through direct experience.

APRIL 28

**School Health Contents Training** for Lower Secondary course

- Opening Ceremony
- School health lecture by Professors from Japan

APRIL 29

**Field Trip**

- School visit
- School health activities by lecturers

APRIL 30

**Translation Workshop** for School Health Textbook

- Glossary review
- Group work, shared ideas

## Intensive, meaningful and fruitful training

Siem Reap was intentionally chosen as the venue for this training to provide a focused environment where lecturers and staff could fully concentrate on the content without distraction or additional responsibilities. With this setting, the three-day program was designed to be intensive, meaningful, and fruitful.
Although the duration is short, the expectation is clear—that every session, discussion, and field experience will contribute to deeper understanding and practical impact.



**Ms. Masuko Yuka, Country Director of STEP**



## Health, Peace and the Future of Education

The second STEP School Health training in Siem Reap opened as more than a technical workshop, but as a reflection on the close link between peace and education. In the context of recent conflict near Siem Reap, participants were reminded that instability affects not only safety and health, but also children's learning, family life, and community well-being. Guided by the WHO concept of "Health for Peace," the session emphasized how education can help build trust, reduce tension, and nurture hope for a more peaceful future.

The discussion also highlighted the importance of local ownership in education, particularly in the development of school health textbooks in Cambodia. Participants reflected that meaningful education must be grounded in local realities, culture, and experiences.
Supported by The Nippon Foundation, the initiative was presented as a starting point, with its long-term impact depending on the continued engagement of Cambodian educators in shaping and strengthening school health education.
The training concluded with a shared commitment to advancing both peace and the future of education in Cambodia.

**Dr. Asakura Takashi, Chairperson of STEP**

## \ RADIO EXERCISE /

STEP training sessions begin each day with Radio Exercise (a traditional Japanese exercise routine). The morning exercise helps us start the day feeling refreshed.







## Guest Remark by Ministry of Education, Youth and Sport



### Commitment to Advancing School Health Education

The training opened in a warm and respectful atmosphere, led by H.E. Dr. Yung Kunthearith, Deputy Director of the School Health Department, who expressed sincere appreciation to The Nippon Foundation for its continued support.

Speaking from Siem Reap Province, he highlighted the city's historical and cultural significance and extended appreciation to Dr. Asakura Takashi for his reflections on the Thailand-Cambodia conflict, acknowledging its sensitivity, particularly for families affected by loss and displacement.

He thanked STEP staff and TEC lecturers for their dedication and active participation, and emphasized the importance of the three-day training. He also encouraged ownership of the 24-credit textbook development process, especially in translation and implementation, highlighting quality, clarity, visuals, and readability for effective student learning.

At the end of his remark, he shared recognition from the Ministry of Education, Youth and Sport for the ongoing efforts of STEP and TEC lecturers, as well as its anticipation of future SHCC Phase 2 outcomes. He concluded with a strong message of encouragement, urging all participants to continue striving for excellence in advancing school health education for Cambodia's future generations.

**H.E. Dr. Yung Kunthearith**
**Deputy Director of Department of School Health, MoEYS**

## Textbook Contents Lecture

### School Health and School Safety

The first technical session explored essential concepts of school health and safety. Facilitated by expert school health lecturers, participants deepened their understanding of how safe and healthy school environments contribute to effective learning and child development.

**by Dr. Saito Chikage and Dr. Aoyagi Naoko**




### Human Anatomy and Physiology

Building on foundational knowledge, the second lecture focused on human anatomy and physiology. Participants enhanced their understanding of the human body, equipping them with the knowledge necessary to effectively teach health education in TECs.

**by Dr. Aoyagi Naoko**






*TECs expresses its appreciation to The Nippon Foundation, STEP, educators, and community stakeholders for their continued cooperation and resilience in supporting the needs of displaced students and families.*

The recent conflict along the Cambodia border has significantly affected families and communities, including two TECs MoU partner schools: **Bos Thom Primary School** (PTEC) and **Tamon Sen Chey Primary School** (BTEC), both of which have experienced major disruption. Many students, teachers, and families have been displaced, with children continuing their education in temporary learning spaces and tent classrooms. Despite these challenges, students remain committed to learning.

In response, STEP visited the target schools and worked with School Health lecturers to deliver health and hygiene activities, including **physical exercise, handwashing**, and **oral hygiene promotion**, to support students' well-being during displacement.









## Reflection of the Field Trip

Following the school visits, School Health lecturers reflected on the challenges faced by displaced students and the importance of continued education and health support during this difficult period.
They expressed appreciation for the resilience of students, teachers, and families, noting that children in temporary tent classrooms remained actively engaged and eager to learn. The visits also reinforced the importance of hygiene and well-being in emergency learning settings. Activities such as physical exercise, handwashing, and oral hygiene were used to promote healthy habits and support students' emotional well-being.
TECs and its partners continue to provide support to affected schools and communities where possible, focusing on education, health awareness, and student well-being.







## Translation Workshop for School Health Textbook

### Bridging Knowledge: Enhancing Quality through Collaborative Translation

A translation workshop was organized to support the collaborative improvement of textbook content and strengthen the quality of educational materials. The session brought together participants to work collectively on reviewing key terminology through glossary refinement, ensuring accurate and consistent usage across materials.
In addition, practical translation exercises were conducted to enhance participants' applied skills and promote a shared understanding of effective translation practices. Group discussions and peer feedback were also integrated to identify areas for improvement and to refine translation approaches.
Overall, the workshop contributed to strengthening translation standards, improving clarity and consistency, and supporting the development of higher-quality learning resources for classroom implementation.


Glossary Review


Refining Translation Rules and Template


Mini translation exercise

## Reflections from MoEYS




**Mr. Mon Munint**
**Director of Department of Teacher Education**

The second STEP School Health Training in Siem Reap opened with key reflections from stakeholders, setting a shared direction for strengthening school health education in Cambodia.
Speakers highlighted continuous improvement, the role of health education in promoting peace and resilience, and the importance of quality and consistency in textbook development, including standardized tools such as templates and a common glossary.

Technical sessions led by Dr. Saito Chikage and Dr. Aoyagi Naoko covered School Health and School Safety, and Human Anatomy and Physiology through interactive methods such as case studies and group discussions.
Overall, the training emphasized aligning technical content with practical classroom realities to ensure school health materials are relevant and usable in Cambodian schools.



**“Bright Futures Under Every Tent”**
***Sharing learning materials and creating opportunities for every child***

## Closing Remark by TEC Management Team

**Dr. Sam Chanphirun**
**Deputy Director of Teacher Education College**



On the final day of the training, Dr. Sam Chanphirun presided over the closing session, fostering a sense of reflection and shared purpose. He encouraged School Health lecturers to remain committed, proactive, and creative in advancing STEP’s mission, emphasizing their key role in shaping a healthier generation of students, and expressed sincere appreciation to The Nippon Foundation and NGO STEP for their continued support to TECs, highlighting the strength of their trusted partnership.

Reflecting on the journey so far, he expressed hope that STEP would continue to grow in visibility and impact at the national level, with strong support from TECs. Key future directions were also proposed, including an Annual School Health Forum, stronger community and institutional engagement, practical learning opportunities for student teachers, and expanded national and online platforms for stakeholder exchange.
The session concluded with a vision of a **“Happy and Healthy STEP Community,”** where collaboration is embedded in practice and the well-being of students, teachers, and communities remains central.